# របាយការណ៍
## ស្តីពី
## លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែសីហា ឆ្នាំ២០២៣

នៅក្នុងខែសីហា ឆ្នាំ២០២៣នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅ៖

### ១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

១.១-សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា

-បានបំពេញភារកិច្ចជាប្រមុខរដ្ឋស្តីទី ចំនួន០១លើក។

១.១.១-បដិសណ្ឋារកិច្ចឡើវជាតិ-អន្តរជាតិ

-បានអនុញ្ញាតឱ្យឯកអគ្គរាជទូតតែងតាំងថ្មីនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំបណ្តាប្រទេសជាមិត្ត ចំនួន០៧រូប ចូលជួបសម្តែងការគួរសម និងជម្រាបលា នៅវិមានព្រឹទ្ធសភា។

១.១.២-សកម្មភាពចូលរួមពិធីផ្សេងៗ

-បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបើកសម័យប្រជុំដំបូង នៃរដ្ឋសភា នីតិកាលទី៧ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នាសាលប្រជុំពេញអង្គ នៃរដ្ឋសភា

-បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសច្ចាប្រណិធាន សមាជិក សមាជិកានៃរដ្ឋសភា អាណត្តិទី៧ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ ព្រះបរមរាជវាំង

-បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសច្ចាប្រណិធាន សមាជិក សមាជិកានៃរាជរដ្ឋាភិបាលកម្ពុជា អាណត្តិទី៧ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ ព្រះបរមរាជវាំង

-បានអញ្ជើញចូលរួមដង្ហែព្រះរាជដំណើរ**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ**



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441. 211 442. 211 443 ទូរសារ: (855 23) 211 446. E-mail: oum_sarith@camnet.com.kh

**សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ស្តេចយាងពិនិត្យ និងព្យាបាលព្រះរាជសុខភាពនៅទីក្រុងប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ

-បានដឹកនាំគណៈប្រតិភូព្រឹទ្ធសភា អញ្ជើញគោរពវិញ្ញាណក្ខន្ធសពឯកឧត្តម **សំ ព្រហ្មនា** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ នៅរាជធានីភ្នំពេញ។

១.១.៣-ពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗ ចំនួន១៥ច្បាប់ និងជ្រាបជាព័ត៌មាន ចំនួន១៧ច្បាប់។

**១.២-ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ឹម កា អនុប្រធានទី១ ព្រឹទ្ធសភា**

-បានទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភា ចំនួន០១លើក។

១.២.១-សកម្មភាពចូលរួមពិធីផ្សេងៗ

-បានអញ្ជើញជាកិត្តិយសក្នុងពិធីបើកសម័យប្រជុំដំបូង នៃរដ្ឋសភា នីតិកាលទី៧ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នាសាលប្រជុំពេញអង្គ នៃរដ្ឋសភា។

១.២.២-សកម្មភាពចុះមូលដ្ឋាន

-បានអញ្ជើញនាំយកទៀនចំណាំព្រះវស្សា ព្រមទាំងទេយ្យវត្ថុ គ្រឿងឧបភោគ បរិភោគ និងបច្ច័យមួយចំនួន ទៅវេរប្រគេនព្រះសង្ឃគង់ចាំព្រះវស្សា ចំនួន០២វត្ត រួមមាន៖ វត្តទេពនិម្មិត ហៅវត្តអញ្ចាញ ស្ថិតនៅឃុំក្របៅ ស្រុកកំចាយមារ និងវត្តពង្សរង្សី ហៅវត្តជ្រៃម្រាក់ ស្ថិតនៅឃុំគោកគង់កើត ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង។

១.២.៣-ពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗ ចំនួន១៧ច្បាប់ និងជ្រាបជាព័ត៌មាន ចំនួន៣៥ច្បាប់។

**១.៣-ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា**

១.៣.១-សកម្មភាពចូលរួមពិធីផ្សេងៗ

-បានអញ្ជើញដឹកនាំគណៈប្រតិភូសភាកម្ពុជាទៅចូលរួមមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៤ (AIPA- 44) ក្រោមប្រធានបទស្តីពី ការឆ្លើយតបសភាដើម្បីស្ថិរភាព និងវិបុលភាពអាស៊ាន នៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី។ ក្នុងឱកាសនេះ ឯកឧត្តមប្រធានគណៈប្រតិភូបាន៖ ពិភាក្សាការងារជាមួយ ឯកឧត្តម ZHU YONGGUAN សមាជិកសភាតំណាង

ប្រជាជនចិននៃសាធារណរដ្ឋប្រជាមានិតចិន, ពិភាក្សាការងារទ្វេភាគីជាមួយ លោកជំទាវ SOUNTHONE XAYACHACK អនុប្រធានរដ្ឋសភានៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ, ពិភាក្សាការងារទ្វេភាគីជាមួយ ឯកឧត្តម **វឿង ឌីញហ្វេ** ប្រធានរដ្ឋសភានៃសាធារណរដ្ឋសង្គមនិយមវៀតណាម

-បានអញ្ជើញជាកិត្តិយសក្នុងពិធីបើកសម័យប្រជុំដំបូង នៃរដ្ឋសភា នីតិកាលទី៧ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នាសាលប្រជុំពេញអង្គ នៃរដ្ឋសភា

-បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធបើកឱ្យប្រើប្រាស់ជាផ្លូវការផ្លូវក្រវ៉ាត់ក្រុងទី៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅខេត្តកណ្តាល។

១.៣.២-សកម្មភាពចុះមូលដ្ឋាន

-បានអនុញ្ញាតឱ្យក្រុមការងារដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តមកពីប្រទេសបារាំងចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋឥតគិតថ្លៃ នៅខេត្តកណ្តាល។

១.៣.៣-ពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗ ចំនួន១៣ច្បាប់ និងជ្រាបជាព័ត៌មាន ចំនួន១០ច្បាប់។

## ២-គណៈកម្មការនានារបស់ព្រឹទ្ធសភា

សមាជិក សមាជិកាព្រឹទ្ធសភាបានបំពេញការងារតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម៖

### ២.១-មុខងារនីតិកម្ម

-បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដឹកនាំដោយឯកឧត្តម **ចាន់ សុធី** និងឯកឧត្តម **ម៉ឹង មករា** រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងពិភាក្សាលើគម្រោងថវិកាប្រចាំឆ្នាំ២០២៤ របស់ព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា។

### ២.២-មុខងារតំណាង

-បានទទួលពាក្យបណ្តឹង ចំនួន០២ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹង ចំនួន០២ករណី កំពុងពិនិត្យសិក្សា ចំនួន០២ករណី ឆ្លើយតបទៅម្ចាស់បណ្តឹង ចំនួន០៥ករណី ព្រមទាំងបានទទួលឯកសារជូនជ្រាបពីក្រសួង-ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការ ចំនួន០១ករណី

-បានអញ្ជើញដាក់កម្រងផ្កា គោរពវិញ្ញាណក្ខន្ធសពឯកឧត្តម **សំ ព្រហ្មនា** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដឹកនាំដោយសម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៅរាជធានីភ្នំពេញ

-បានអញ្ជើញចូលរួមក្នុងពិធីបើកសម័យប្រជុំដំបូង នៃរដ្ឋសភា នីតិកាលទី៧ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នាសាលប្រជុំពេញអង្គ នៃរដ្ឋសភា

-បានអញ្ជើញចូលរួមប្រជុំដើម្បីពិភាក្សាការងារចាំបាច់ចំពោះមុខ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា

-បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធបើកឱ្យប្រើប្រាស់ជាផ្លូវការផ្លូវក្រវ៉ាត់ក្រុងទី៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅខេត្តកណ្ដាល

-បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការ នៃមជ្ឈមណ្ឌលបន្សាបព្យាបាល និងស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀន, ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារសាលាបឋមសិក្សាបាយដំរាំ, ពិធីប្រជុំបូកសរុបលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ នៅខេត្តបាត់ដំបង

-បានអញ្ជើញទទួលព្រះសង្ឃ ចំនួន១០០អង្គ និមន្តមកពីវត្តមហានាមស្លារម តាជី យាយជី សិស្សានុសិស្ស និងប្រជាជនក្រីក្រអញ្ជើញមកទស្សនកិច្ចនៅតំបន់អភិវឌ្ឍន៍កសិទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ ព្រមទាំងបានប្រគេនចង្ហាន់អាហារពេលព្រឹក និងអាហារថ្ងៃត្រង់ និងបច្ច័យមួយចំនួនដល់ព្រះសង្ឃ និងប្រជាពលរដ្ឋផងដែរ

-បានអញ្ជើញទទួលជួបលោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស អញ្ជើញមកពីវិទ្យាស្ថានកសិកម្ម ម៉ុង ឫទ្ធី កែវផុស OMRA ចំនួន១២០នាក់ មកបំពេញទស្សនកិច្ចសិក្សាឈ្វេងយល់វិស័យកសិកម្ម កសិឧស្សាហកម្ម នៅតំបន់អភិវឌ្ឍន៍កសិទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ

-បានអញ្ជើញធ្វើបទបង្ហាញអំពីតួនាទី និងភារកិច្ចរបស់ព្រឹទ្ធសភា ជូនដល់សាស្ត្រាចារ្យ និងនិស្សិត នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ចំនួន៨០នាក់ នៅវិមានព្រឹទ្ធសភា

-ដោយឡែក សមាជិក សមាជិកាព្រឹទ្ធសភាបានអញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ ក្រុមគ្រូពេទ្យ អតីតមន្ត្រីរាជការជានិវត្តជន អតីតយុទ្ធជន យុវជន-យុវនារី ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ នៅមូលដ្ឋាន ឈ្វេងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខសណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធ ជួយប្រជាពលរដ្ឋជួបគ្រោះធម្មជាតិ ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា នៅរាជធានី និងតាមបណ្តាខេត្ត ក្រុងនានា ចំនួន៩៧លើក ព្រមទាំងបានអញ្ជើញជាគណៈអធិបតីក្នុងពិធីសម្ពោធសមិទ្ធផលនានា និងចូលរួមជាកិត្តិយសក្នុងពិធីផ្លូវការផ្សេងៗ ចំនួន៥១លើក។

## ២.៣-កិច្ចសហប្រតិបត្តិការអន្តរជាតិ

ការងារសហប្រតិបត្តិការអន្តរជាតិរបស់ព្រឹទ្ធសភា ជាពិសេស ទំនាក់ទំនងក្នុងកម្រិតតំបន់ និងអន្តរជាតិ សមាជិក សមាជិកាព្រឹទ្ធសភា បានចូលរួមយ៉ាងសកម្ម និងទទួលបានលទ្ធផលជាវិជ្ជមានដូចខាងក្រោម៖

-បានអញ្ជើញចូលរួមមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៤ (AIPA-44) ក្រោមប្រធានបទស្តីពីការឆ្លើយតបសភា ដើម្បីស្ថិរភាព និងវិបុលភាពអាស៊ាន នៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី

-បានអញ្ជើញចូលរួមកិច្ចប្រជុំនៃវេទិកាសមាជិកសភាអាស៊ី-ប៉ាស៊ីហ្វិកលើកទី៧ ស្តីពីសុខភាពសកល (APPFGH-7) នៅទីក្រុងអ៊ូឡង់បាទ័រ ប្រទេសម៉ុងហ្គោលី

-បានអញ្ជើញចូលរួមក្នុងពិធីជំនួបពិភាក្សាការងាររវាងឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា និងជាប្រធានគណៈប្រតិភូជាមួយ ឯកឧត្តម ZHU YONGGUAN សមាជិកសភាតំណាងប្រជាជនចិននៃសាធារណរដ្ឋប្រជាមានិតចិន

-បានអញ្ជើញទទួលជួបក្រុមវិនិយោគមកពីប្រទេសសិង្ហបុរីអញ្ជើញចុះមកទស្សនកិច្ច និងពិនិត្យសិក្សាឈ្វេងយល់អំពីវិស័យកសិកម្ម កសិឧស្សាហកម្ម ប្រព័ន្ធធារាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធនានា នៅតំបន់អភិវឌ្ឍន៍កសិទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ

-បានអញ្ជើញទទួលជួបក្រុមវិនិយោគជនជាតិជប៉ុន ដែលមានបំណងចង់បង្កើតមជ្ឈមណ្ឌលមើលថែប្រជាពលរដ្ឋចាស់ជរានៅតំបន់អភិវឌ្ឍន៍ កសិទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ

-បានអញ្ជើញជួបសម្តែងការគួរសម និងពិភាក្សាការងាររវាងគណៈកម្មការទី៣ ព្រឹទ្ធសភាជាមួយ លោក Kansuke otani អតីតសមាជិកសភាប្រចាំខេត្តហ៊ីយ៉ូហ្គូ និងជានាយកមជ្ឈមណ្ឌលផ្លាស់ប្តូរអាស៊ីជប៉ុន នៅវិមានព្រឹទ្ធសភា

-បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីអបអរសាទរបុណ្យជាតិខួបលើកទី៥៨របស់ប្រទេសសិង្ហបុរី ដែលរៀបចំឡើងដោយ ឯកឧត្តម Two Lay Cheng ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃប្រទេសសិង្ហបុរី ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា នៅរាជធានីភ្នំពេញ

-បានអញ្ជើញចូលរួមជាកិត្តិយក្នុងពិធីអបអរសាទរខួបលើកទី៧៧ នៃទិវាបុណ្យឯករាជ្យជាតិឥណ្ឌា ដែលរៀបចំឡើងដោយ លោកជំទាវ Dr. Devyani Khobragade ឯកអគ្គរដ្ឋទូតនៃស្ថានទូតឥណ្ឌាប្រចាំនៅព្រះរាជាណាចក្រកម្ពុជា នៅរាជធានីភ្នំពេញ។

ថ្ងៃ ចន្ទ ៤ រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ២០២៣

ជ.ប្រធានស្តីទីព្រឹទ្ធសភា

អនុប្រធានទី២

**កិត្តិសង្គហបណ្ឌិត ទេព ងន**

<u>ចម្លងជូន</u>

- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន

(ជូនជ្រាបជាព័ត៌មាន)

- កាលប្បវត្តិ-ឯកសារ